# តើការតាមដានការប៉ះពាល់ដំណើរការយ៉ាងដូចម្ដេច

ការតាមដានការប៉ះពាល់ (Contact tracing) គឺជាដំណើរការដ៏សាមញ្ញ ជាសម្ងាត់ដែលត្រូវបានប្រើដោយនាយកដ្ឋានសុខភាពសាធារណៈអស់រយៈពេលជាច្រើនទសវត្សដើម្បីពន្យឺតការរីករាលដាលនៃជំងឺឆ្លង និងចៀសវាងការផ្ទុះជំងឺ។ អ្នកអាចចូលរួមបានដោយឆ្លើយតបពីរបីសំណួរងាយៗនៅពេល Public Health ទូរស័ព្ទទៅ។

## បើអ្នកធ្វើតេស្តវិជ្ជមានសម្រាប់ជំងឺ COVID-19



- **ស្ថិតនៅផ្ទះ លើកលែងតែដើម្បីទទួលបានការថែទាំវេជ្ជសាស្ត្រ និងនៅឲ្យឆ្ងាយពីអ្នកដទៃរហូតដល់៖**
  - យ៉ាងតិចបំផុត 10 ថ្ងៃបានកន្លងផុតចាប់តាំងពីពេលអ្នកចេញរោគសញ្ញាដំបូង និង
  - អការៈគ្រុនក្ដៅរបស់អ្នកបាត់ទៅវិញយ៉ាងតិចបំផុត 24 ម៉ោង និង
  - រោគសញ្ញារបស់អ្នកមានភាពធូរស្រាល។

- **នាយកដ្ឋានសុខភាពសាធារណៈនឹងទាក់ទងទៅអ្នកដើម្បីធ្វើការតាមដាន។ វាជាការសំខាន់ដែលត្រូវទទួលទូរស័ព្ទនេះ។**



**Public Health នឹងសួរ៖**

1. អំពីទីកន្លែងដែលអ្នកបានទៅ។
2. មនុស្សដែលអ្នកនៅជិត ខណៈពេលអ្នកអាចចម្លងជំងឺបាន។

- **មនុស្សដែលអ្នកប្រាប់មកយើង នឹងត្រូវបានទាក់ទង ប៉ុន្តែនឹងមិនប្រាប់ឈ្មោះ ឬព័ត៌មានទំនាក់ទំនងរបស់អ្នកទេ។ ពួកគេនឹងត្រូវបានស្នើឲ្យស្ថិតនៅផ្ទះដើម្បីទប់ស្កាត់កុំឲ្យអ្នកដទៃឈឺ។**

**ប្រសិនបើអ្នកទទួលបានទូរស័ព្ទពី Public Health នោះអ្នកនឹងឃើញពាក្យ LA PublicHealth ឬ លេខ 1-(833) 641-0305 នៅក្នុងទូរស័ព្ទរបស់អ្នក។**

www.publichealth.lacounty.gov

## បើអ្នកបានប៉ះពាល់ជាមួយនរណាម្នាក់ដែលមានជំងឺ COVID-19៖

- **ស្ថិតនៅផ្ទះរយៈពេល 14 ថ្ងៃបន្ទាប់ពីការប៉ះពាល់ចុងក្រោយរបស់អ្នកជាមួយមនុស្សដែលមានជំងឺ COVID-19។**

- **នាយកដ្ឋានសុខភាពសាធារណៈ នឹងទូរស័ព្ទទៅអ្នកដើម្បីធ្វើការតាមដាន។ វាជាការសំខាន់ដែលត្រូវទទួលទូរស័ព្ទនេះ។**



**Public Health នឹងសួរ៖**

1. ថាតើអ្នកកំពុងមានរោគសញ្ញា ឬថាតើអ្នកបានធ្វើតេស្តឬក៏អត់។
2. អំពីទីកន្លែងដែលអ្នកបានទៅផងដែរ។

- **ដើម្បីចៀសវាងការច្រឡំថាអ្នកគឺជាមនុស្សផ្សេងទៀត សូមផ្ដល់ព័ត៌មានពេញលេញ និងត្រឹមត្រូវរបស់អ្នកឲ្យពួកគេ។**
- **ពួកគេអាចទូរស័ព្ទទៅអ្នកច្រើនជាងម្ដងដើម្បីពិនិត្យថាអ្នកមានសុខទុក្ខយ៉ាងណាក្នុងអំឡុងពេល 14 ថ្ងៃដែលអ្នកស្ថិតនៅផ្ទះ។**
- **ពួកគេនឹងផ្ដល់ឲ្យអ្នកនូវព័ត៌មានអំពីជំហានបន្ទាប់ដោយផ្អែកលើការឆ្លើយតបរបស់អ្នក។**
- **ពួកគេក៏នឹងផ្ដល់ឲ្យអ្នកនូវព័ត៌មានអំពីរបៀបទទួលបានសេវាកម្មដូចជាការធ្វើតេស្តសម្រាប់ជំងឺ COVID-19 ឬរបៀបស្វែងរកគ្រូពេទ្យបើសិនជាអ្នកមិនទាន់មានគ្រូពេទ្យនៅឡើយ។**




County of Los Angeles Public Health

7-23-2020 (Cambodian)